# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី ការកែតម្រូវព័ត៌មានដែលបានចេញផ្សាយអំពី
## ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ២៦នាក់ និងជាសះស្បើយ ០៤នាក់
## នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០

ដោយសារមានការទើបទទួលបានព័ត៌មានផ្ទៀងផ្ទាត់ជាក់លាក់អំពីព័ត៌មានអ្នកដំណើរ ក្រសួងសុខាភិបាល សូមធ្វើការកែតម្រូវនូវព័ត៌មានមួយចំនួន ដែលមានដាក់ពណ៌លឿង (ដើម្បីងាយស្រួលកត់សម្គាល់កន្លែងដែលត្រូវកែតម្រូវ) និងសូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖**

គិតត្រឹមម៉ោង ០៧:០០ព្រឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **១៤០នាក់** (ស្មើនឹង ៧១,០៧% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះមានស្រី ៣៩នាក់ និងបុរស ១០១នាក់
- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **១៩៧នាក់** (ស្ត្រី ៤៣នាក់ និងបុរស ១៥៤នាក់។ សូមបញ្ជាក់ថា៖ ក្រសួងសុំកែតម្រូវតួលេខស្ត្រីពីចំនួន ៤២នាក់ មក ៤៣នាក់វិញ ដោយសារក្រសួងទើបតែទទួលបានព័ត៌មានពីស្ថានទូតអាមេរិកនៅកម្ពុជាថា មន្ត្រីការទូតអាមេរិកកាំងវិជ្ជមានវីរុសកូវីដ-១៩ជាស្ត្រីទាំង ០២នាក់ (ម្នាក់អាយុ ២៧ឆ្នាំ និងកុមារអាយុ ១៥ខែ ម្នាក់)
- អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋ មានចំនួនសរុប ៥៥នាក់៖
  - នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មានចំនួន ០៧នាក់ (ស្ត្រី ០១នាក់ និងបុរស ០៦នាក់) ជាករណីដែលបានវិលត្រឡប់មកពីប្រទេសឥណ្ឌូណេស៊ី និង
  - នៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ សរុបចំនួន ៤៨នាក់ ដែលបុរសចំនួន ១៩នាក់ ជាករណីដែលបានវិលត្រឡប់មកពីប្រទេសអារ៉ាប៊ីសាអ៊ូឌីត បុរស ០២នាក់ និងស្ត្រី ០១នាក់ ដែលបានវិលត្រឡប់មកពីសហរដ្ឋអាមេរិក និងបុរសចំនួន ២៥នាក់ ជាករណីវិជ្ជមានវីរុសកូវីដ-១៩ ដែលវិលត្រឡប់មកពីប្រទេសអេហ្ស៊ីប ប្រទេសរុស្ស៊ី តាមជើងហោះហើរម៉ាឡេស៊ី និងបុរស ០១នាក់ទៀត ជាអ្នកដំណើរមកពីប្រទេសបារាំងដោយឆ្លងកាត់ប្រទេសកូរ៉េខាងត្បូង
- អ្នកសម្រាកព្យាបាលនៅបន្ទប់ដោយឡែកក្នុងស្ថានទូតអាមេរិកប្រចាំកម្ពុជា៖ ជាស្ត្រីជនជាតិអាមេរិកកាំង ០២នាក់។



ទីស្តីការក្រសួងសុខាភិបាលដីឡូត៍លេខ៨០ វិថីសម្តេចប៉ែននុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

**២. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖** បុរសជនជាតិខ្មែរ ចំនួន ២៦នាក់ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០

- អាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅបុរីប៉េងហួត បឹងស្នោរ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
- អាយុ ២៦ឆ្នាំ មានអាស័យដ្ឋាននៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
- អាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅភូមិព្រៃចង្ក្រាកើត ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ
- អាយុ ៣២ឆ្នាំ មានអាស័យដ្ឋាននៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប
- អាយុ ៣១ឆ្នាំ មានអាស័យដ្ឋាននៅសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
- អាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅភូមិបឹងសាឡាង សង្កាត់សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
- អាយុ ២៨ឆ្នាំ មានអាស័យដ្ឋាននៅភូមិថ្លុកព្រីង ឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង
- អាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅភូមិ៣ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- អាយុ ២៨ឆ្នាំ មានអាស័យដ្ឋាននៅភូមិក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- អាយុ ២៧ឆ្នាំ មានអាស័យដ្ឋាននៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
- អាយុ ២៧ឆ្នាំ មានអាស័យដ្ឋាននៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប
- អាយុ ២៦ឆ្នាំ មានអាស័យដ្ឋាននៅភូមិប៉ប្រកខាងជើង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- អាយុ ២៨ឆ្នាំ មានអាស័យដ្ឋាននៅភូមិប្រសូត ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង
- អាយុ ២៦ឆ្នាំ មានអាស័យដ្ឋាននៅបុរីចំការដូង ភូមិរការ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ
- អាយុ ២៩ឆ្នាំ មានអាស័យដ្ឋាននៅ ផ្លូវ២៧១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ
- អាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅភូមិព្រៃគុប សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
- អាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅភូមិព្រៃគុប សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
- អាយុ ២៦ឆ្នាំ មានអាស័យដ្ឋាននៅភូមិសន្សំកុសល់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
- អាយុ ២៦ឆ្នាំ មានអាស័យដ្ឋាននៅបុរីចំការដូង១ ភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ
- អាយុ ២៧ឆ្នាំ មានអាស័យដ្ឋាននៅសង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
- អាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
- អាយុ ៣២ឆ្នាំ មានអាស័យដ្ឋាននៅភូមិស្រឡៅជ្រុំ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង
- អាយុ ២៤ ឆ្នាំ មានអាស័យដ្ឋាននៅភូមិជំនីក ឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
- អាយុ ៣០ឆ្នាំ មានអាស័យដ្ឋាននៅភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
- អាយុ ២៧ ឆ្នាំ មានអាស័យដ្ឋាននៅភូមិ ព្រែកបាក់ ឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម
- អាយុ ៦៥ ឆ្នាំ មានអាស័យដ្ឋានៅភូមិ៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម

**សម្គាល់៖**

***ក. សរុបអ្នកវិជ្ជមានវីរុសកូវីដ-១៩ ទាំង ២៦នាក់ខាងលើ*** ចែកចេញជា៖

- បុរស ០៣នាក់ ជាអ្នកធ្វើដំណើរតាមជើងហោះហើរមកពីប្រទេសអេហ្ស៊ីប និងបុរស ២០នាក់ទៀត ជាអ្នកធ្វើដំណើរតាមជើងហោះហើរមកពីប្រទេសរុស្ស៊ី ដែលបានបន្តជើងហោះហើរនៅប្រទេសម៉ាឡេស៊ី (MH754) និងបុរស ០២នាក់ ជាអ្នកធ្វើដំណើរតាមជើងហោះហើរមកពីប្រទេសម៉ាឡេស៊ី មកដល់កម្ពុជានាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង១២:៥៥នាទីរសៀល។ តាមជើងហោះហើរនេះ មានអ្នក

ដំណើរសរុបចំនួន ១៤៤នាក់ (មានស្រី ០៧នាក់) ដែលមានជនជាតិខ្មែរ ១៤៤នាក់ (មានស្រី ០៧នាក់)។ នៅក្នុងចំនួនសរុបទាំងអស់នេះ មានអ្នកដំណើរមកពីប្រទេសអេហ្ស៊ីបចំនួន ៣៥នាក់ (មានស្រី ០៥នាក់) មកពីប្រទេសរុស្ស៊ីចំនួន ១០០នាក់ (ស្រី ០១នាក់) និងមកពីប្រទេសម៉ាឡេស៊ីចំនួន ០៩នាក់ (ស្រី ០១នាក់)។

- បុរស ០១នាក់ទៀត ជាអ្នកធ្វើដំណើរមកពីប្រទេសបារាំងដោយឆ្លងកាត់ប្រទេសកូរ៉េខាងត្បូង មកដល់ កម្ពុជានាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង០៩:៤៥នាទីយប់។ ជើងហោះហើរនេះ មានអ្នកដំណើរសរុបចំនួន ១១០នាក់ (មានស្រី ៤៦នាក់ និងប្រុស ៦៤នាក់ ដែលក្នុងចំនួននេះ មានក្មេងចំនួន ១៦នាក់) ដែលមានជនជាតិខ្មែរចំនួន ៣៨នាក់ (ស្រី ១៣នាក់ ប្រុស ២៥នាក់) ជនជាតិអាមេរិកកាំង ១៩នាក់ (ស្រី១១នាក់ ប្រុស ០៦នាក់ និងក្មេង ០២នាក់) ជនជាតិស៊ុយអែត ០៦នាក់ (ស្រី ០១នាក់ ប្រុស ០៣នាក់ និងក្មេង ០២នាក់) ជនជាតិកូរ៉េ ០៨នាក់ (ស្រី ០៤នាក់ ប្រុស ០៤នាក់) ជនជាតិបារាំង ២៣នាក់ (ស្រី ០៩ ប្រុស ១៤នាក់) ជនជាតិចិន ០១នាក់ (ប្រុស) ជនជាតិកាណាដា ០២នាក់ (ស្រី ០១នាក់ ប្រុស ០១នាក់) ជានជាតិអង់គ្លេស ០១នាក់ (ប្រុស) ជនជាតិអូស្ត្រាលី ០២នាក់ (ស្រី០១ ប្រុស០១នាក់) ជនជាតិអូប៊េគីស្តង់ ០១នាក់ (ស្រី) ជនជាតិទួកគី ០១នាក់ (ប្រុស) ជនជាតិវៀតណាម ០១នាក់ (ប្រុស) ជនជាតិស្វីស ០២នាក់ (ប្រុស) ជនជាតិអាហ្វ្រិកខាងត្បូង ០២នាក់ (ស្រី០១នាក់ ប្រុស ០១នាក់) និងជនជាតិប៉ូឡូញ ០៣នាក់ (ស្រី ០១នាក់ និងក្មេងស្រី ០២នាក់)។ អ្នកដំណើរទាំងអស់នេះបានចាកចេញមកពីប្រទេសចំនួន ១០ គឺមានប្រទេសកូរ៉េ (២៩នាក់) សហរដ្ឋអាមេរិក (២៦នាក់) ប្រទេសកាតា (០២នាក់) ប្រទេសថៃ (០៣នាក់) ប្រទេសអូស្ត្រាលី (០២នាក់) ប្រទេសអារ៉ាប់រួម (០៣នាក់) ប្រទេសបារាំង (៣០នាក់) ប្រទេសអាល្លឺម៉ង់ (១១នាក់) ប្រទេសហូឡង់ (០២នាក់) និងប្រទេសកាណាដា (០២នាក់)។

**ខ. ការវិភាគវត្ថុសំណាករបស់ពួកគាត់ទាំងអស់ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា** ទទួលបានលទ្ធផលវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ២៦នាក់ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០។ បច្ចុប្បន្ន អ្នកជំងឺទាំង ២៦នាក់ខាងលើនេះ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

**គ. អ្នកដំណើរដែលមានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ៖**

- អ្នកដំណើរតាមជើងហោះហើរកូរ៉េចំនួន ១០៩នាក់ ដែលមានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ត្រូវបានចែកចេញដាក់ឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័កទីពអាកាសក្នុងរាជធានីភ្នំពេញចំនួន ២០នាក់ និងនៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញ ចំនួន ៨៩នាក់
- អ្នកដំណើរមកពីប្រទេសអេហ្ស៊ីប និងប្រទេសរុស្ស៊ី បានមកបន្តជើងហោះហើរនៅប្រទេសម៉ាឡេស៊ី ចំនួន ១១៩នាក់ (មានស្រី ៧នាក់) ដែលមានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័កវិទ្យាល័យសម្តេច ហ៊ុន សែន បុរី ១០០ខ្នង ក្នុងរាជធានីភ្នំពេញ។

**៣. ករណីជាសះស្បើយ៖ បុរសជនជាតិខ្មែរ ចំនួន ០៤នាក់ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០**

- បុរសអាយុ ២៦ឆ្នាំ មានអាស័យដ្ឋាននៅភូមិដំណាក់ពពេល ឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
- បុរសអាយុ ២៧ឆ្នាំ មានអាស័យដ្ឋាននៅភូមិសោយ១ ឃុំប៉ឺស១ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
- បុរសអាយុ ២៨ឆ្នាំ មានអាស័យដ្ឋាននៅភូមិ៦ ឃុំកោះខ្នុរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

បុរសទាំង ០៣នាក់ ខាងលើ ជាអ្នកធ្វើដំណើរតាមជើងហោះហើរមកពីប្រទេសអារ៉ាប៊ីសាអូឌីត

ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

- បុរសអាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅភូមិអូគ្រាវ ឃុំអណ្ដូងថ្ម ស្រុកព្រៃនប់ ព្រះសីហនុ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌូណេស៊ី បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់គន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃព្រហស្បតិ៍ [illegible]ពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០